ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះតុលាការកំពូល

Supreme Court Chamber

Chambre de la Cour suprême

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

Case File/Dossier N°. 002/19-09-2007-ECCC/SC

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 06-Dec-2019, 13:57
CMS/CFO: Sann Rada

**នៅចំពោះមុខ៖**

**ចៅក្រម គង់ ស្រ៊ីម ប្រធាន**
**ចៅក្រម Chandra Nihal JAYASINGHE**
**ចៅក្រម សោម សិរីវឌ្ឍ**
**ចៅក្រម Florence Ndepele Mwachande MUMBA**
**ចៅក្រម ម៉ុង មុន្នីចរិយា**
**ចៅក្រម Maureen Harding CLARK**
**ចៅក្រម យ៉ា ណារិន**

**កាលបរិច្ឆេទឯកសារ៖** **ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៩**
**ភាសាដើម៖** **ខ្មែរ/អង់គ្លេស**
**ចំណាត់ថ្នាក់ឯកសារ៖** **សាធារណៈ**

---

# សេចក្តីសម្រេចលើសំណើពាក់ព័ន្ធនឹងសារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងបណ្តឹងសាទុក្ខរបស់ ខៀវ សំផន

---

**<u>សហព្រះរាជអាជ្ញា</u>**

ជា លាង

Brenda HOLLIS

**<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ

Megan HIRST

**<u>ជនជាប់ចោទ</u>**

ខៀវ សំផន

**<u>សហមេធាវីជនជាប់ចោទ ខៀវ សំផន</u>**

គង់ សំអុន

Anta GUISSÉ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ឯកសារលេខ F52/1

**អង្គជំនុំជម្រះតុលាការកំពូល**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែលបានប្រព្រឹត្តក្នុងអំឡុង ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ (“អង្គជំនុំជម្រះតុលាការកំពូល” និង “អ.វ.ត.ក”) បានទទួល សំណើពាក់ព័ន្ធនឹងសារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងបណ្តឹង សាទុក្ខរបស់ ខៀវ សំផន (“សំណើសុំ”)[1]។

## I. សាវតារ

1. នៅថ្ងៃទី១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២ និងបានសម្រេចដាក់ពិរុទ្ធភាព នួន ជា និង ខៀវ សំផន ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការ រំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ និងអំពើប្រល័យពូជសាសន៍ ដោយបានសម្រេច ដាក់ទោស នួន ជា និង ខៀវ សំផន អស់មួយជីវិត[2]។ អង្គជំនុំជម្រះសាលាដំបូងបានផ្តល់សេចក្តីសង្ខេបនៃ សម្អាងហេតុរបស់ខ្លួន និងបានបំភ្លឺថា កាលបរិច្ឆេទសម្រាប់ដាក់សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខ ត្រូវ គិតបន្ទាប់ពីការជូនដំណឹងនៃសាលក្រមមានសម្អាងហេតុពេញលេញ[3]។ បន្ទាប់មក អង្គជំនុំជម្រះសាលា ដំបូងបានជូនដំណឹងអំពីសាលក្រមដែលមានសម្អាងហេតុពេញលេញ ជាភាសាខ្មែរ អង់គ្លេស និងបារាំងនៅ ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៩[4]។

---

[1] សំណើពាក់ព័ន្ធនឹងសារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៩ ឯកសារលេខ F52 (“សំណើសុំ”)។

[2] *សូមមើល* ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E1/259.1 (ការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២) ទំព័រ ៣៨ (ជួរ ២៥) ដល់ ៤១ (ជួរ ១០)។

[3] *សូមមើល*ប្រតិចារឹកចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ (ការប្រកាសសាលក្រមក្នុងសំណុំរឿង ០០២/០២) ទំព័រ ២ (ជួរ ២៣) ដល់ ៣(ជួរ ២) និងទំព័រ ៤២ (ជួរ ៧ ដល់ ១៣)។

[4] សាលក្រមអង្គជំនុំជម្រះសាលាដំបូងសំណុំរឿង ០០២/០២ ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៨ ឯកសារលេខ E465 (“សាល ក្រមអង្គជំនុំជម្រះសាលាដំបូង”)។ អង្គជំនុំជម្រះតុលាការកំពូលសម្រេចថា ដោយសារសាលក្រមនេះត្រូវបានដាក់នៅក្រៅម៉ោង សម្រាប់ដាក់ឯកសារផ្លូវការរបស់ អ.វ.ត.ក. ការជូនដំណឹងមានប្រសិទ្ធភាព គឺគិតចាប់ពីថ្ងៃធ្វើការងារបន្ទាប់ គឺនៅថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៩៖ សេចក្តីសម្រេចលើសំណើរបស់ នួន ជា និង ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រលើសេចក្តីជូន ដំណឹងអំពីបណ្តឹងសាទុក្ខ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F43 កថាខណ្ឌ ១២។

2. នៅថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៩ នួន ជា និង ខៀវ សំផន បានដាក់សំណើសុំបន្ថែមចំនួនទំព័រ និងពេលវេលាដើម្បីដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមជាលាយលក្ខណ៍អក្សរ[5]។ អង្គជំនុំជម្រះតុលាការកំពូលបានអនុញ្ញាតជារួមតាមសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៩[6]។

3. នៅថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ នួន ជា និង ខៀវ សំផន បានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២[7]។

4. នៅថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៩ ខៀវ សំផន បានដាក់សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សារណាបណ្ដឹងសាទុក្ខ[8]។ នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៩ សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានដាក់សារណាតប[9] ហើយនៅថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៩ ខៀវ សំផន បានដាក់ការឆ្លើយតបទៅនឹងសារណាតបនេះ[10]។

[5] សំណើបន្ទាន់លើកទីមួយរបស់ នួន ជា សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F40/1.1។ សំណើរបស់មេធាវីការពារក្ដី ខៀវ សំផន សុំបន្ថែមពេលវេលា និងចំនួនទំព័រសម្រាប់ដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F39/1.1។

[6] សេចក្ដីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័ររបស់ នួន ជា និង ខៀវ សំផន ទៅលើសេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០១៩ ឯកសារលេខ F43។

[7] សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០២ ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ E465/3/1។ សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន (០០២/០២) ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ E465/4/1។

[8] សំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងទំព័រដាក់សារណាបណ្ដឹងសាទុក្ខ ថ្ងៃទី ១០ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ F45។

[9] សារណាតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងទំព័រសម្រាប់ដាក់សារណាបណ្ដឹងសាទុក្ខ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ F45/2។ សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទៅនឹងសំណើសុំបន្ថែមពេលវេលា និងទំព័រសម្រាប់សារណាបណ្ដឹងសាទុក្ខ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ F45/1។

[10] ការឆ្លើយតបរបស់ ខៀវ សំផន ទៅនឹងសារណាតបទៅនឹងសំណើសុំបន្ថែមពេលវេលា និងទំព័រសម្រាប់ដាក់សារណាបណ្ដឹងសាទុក្ខ ថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៩ ឯកសារលេខ F45/3។

5. នៅថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៩ អង្គជំនុំជម្រះបានបង្គាប់ឱ្យ ខៀវ សំផន ដាក់សារណាបណ្ដឹងសាទុក្ខមិនឱ្យលើស ៧៥០ ទំព័រ និងមិនឱ្យហួសថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០២០ ជាភាសាអង់គ្លេស ឬ បារាំង ការបកប្រែជាភាសាខ្មែរត្រូវដាក់តាមក្រោយឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន(“សារណាបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន”)។ បន្ថែមលើនេះ អង្គជំនុំជម្រះបានបង្គាប់សហព្រះរាជអាជ្ញាដាក់សារណាតបមិនឱ្យលើស ៣៥០ ទំព័រ តែមួយភាសាក្នុងរយៈពេល ១២០ ថ្ងៃបន្ទាប់ពីការជូនដំណឹងនៃសារណាបណ្ដឹងសាទុក្ខនូវសារណារបស់ ខៀវ សំផន (“សារណាតបរបស់សហព្រះរាជអាជ្ញា”)[11]។

6. នៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៩ សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី(“ដើមបណ្ដឹងរដ្ឋប្បវេណី”) បានដាក់សំណើនេះមកកាន់អង្គជំនុំជម្រះដោយសុំការអនុញ្ញាត៖

ក.ដាក់សារណាតបទៅនឹង ខៀវ សំផន ក្នុងរយៈពេល ៦០ ថ្ងៃ បន្ទាប់ពីការជូនដំណឹងនៃសារណាតបរបស់សហព្រះរាជអាជ្ញា

ខ.បន្ថែមចំនួនទំព័រសម្រាប់សារណាតបរបស់ខ្លួនរហូតដល់ ៣២០ ទំព័រ

គ.ដាក់សារណាតបជាភាសាអង់គ្លេសជាមុន ការបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ[12]។

## II. សារណា

7. ដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងថា ខ្លួនមានអត្ថិភាពតាមច្បាប់ក្នុងការឆ្លើយតបទៅនឹងសារណានៃបណ្ដឹងសាទុក្ខរបស់ ខៀវ សំផន ដោយហេតុថា សារណានោះប៉ះពាល់ដោយផ្ទាល់ទៅលើ “សិទ្ធិជាក់លាក់ និងអត្ថប្រយោជន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី”[13]។

8. ដើមបណ្ដឹងរដ្ឋប្បវេណីបានស្នើសុំដាក់សារណាតបរបស់ខ្លួន ក្នុងរយៈពេល ៦០ ថ្ងៃគិតចាប់ពីការជូនដំណឹងនៃសារណាតបរបស់សហព្រះរាជអាជ្ញា។ ដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងថា រយៈពេល

[11] សេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងទំព័រសម្រាប់ដាក់សារណាបណ្ដឹងសាទុក្ខ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F49 កថាខណ្ឌ ៣៦។

[12] សំណើសុំ ទំព័រ ១១។

[13] សំណើសុំ កថាខណ្ឌ ២ ដល់ ៥, ១២ និង ១៤។

ដែលសុំនេះគឺដើម្បីជៀសវាងការត្រួតគ្នា និងភាពច្រំដែលជាមួយនឹងសារណាតបរបស់សហព្រះរាជអាជ្ញា ហើយពុំបានធ្វើឱ្យមានការពន្យារពេលដោយឥតសមស្របលើកិច្ចដំណើរការនីតិវិធីឡើយ[14]។

9. ដើម្បីឱ្យការចំណាយធនធានកាន់តែមានប្រសិទ្ធភាព និង"ជំរុញកិច្ចដំណើរការនីតិវិធីឱ្យបានឆាប់រហ័ស" ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំដាក់តែភាសាអង់គ្លេស ដែលការបកប្រែជាភាសាខ្មែរនឹងដាក់តាមក្រោយ។ ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា ទាំងនេះពុំបានប៉ះពាល់ដល់កិច្ចសហការរវាងផ្នែកជាតិក្នុងដំណើរការពិគ្រោះពិភាក្សានៅក្នុងអង្គភាព ក្នុងការតាក់តែងសារណាតប និងពុំបានប៉ះពាល់ដល់អត្ថិភាពនៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ជាភាសាខ្មែរដែលត្រូវដាក់ក្នុងពេលវេលាពាក់ព័ន្ធនោះឡើយ[15]។

10. ពាក់ព័ន្ធទៅនឹង"ពាក់ទៅនឹងអត្ថប្រយោជន៍ជាច្រើនដែលដើមបណ្តឹងរដ្ឋប្បវេណីទទួលបានក្នុងការឆ្លើយតប" ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំបន្ថែមរហូតដល់ ៣២០ ទំព័រ និងបានពន្យល់ថា ចំនួនទំព័រនេះ ១) ដោយសារការគណនាទៅលើបញ្ហាជាច្រើននៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន ដែលតម្រូវឱ្យមានការឆ្លើយតបពីដើមបណ្តឹងរដ្ឋប្បវេណី ២) មានការកាត់បន្ថយ ដោយសារ សារណាតបរបស់សហព្រះរាជអាជ្ញា ៣) ប៉ុន្តែ ជាចំនួនមួយដែលមានលក្ខណៈរឹតត្បិត[16]។

## III. ភាពអាចទទួលយកបាន

11. អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចពីដំបូងថា ដើមបណ្តឹងរដ្ឋប្បវេណីមានអត្ថិភាពក្នុងការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តី[17]។

12. ដើម្បីធានាបាននូវសមភាពកម្លាំងតទល់ និងប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី អង្គជំនុំជម្រះបានកម្រិតសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខត្រឹមពីរចំណុចៈ ទីមួយ"អំណះអំណាងដែលបានលើកឡើងនៅក្នុងសារណាតប ត្រូវតែទាក់ទងទៅនឹងទឡ្ហីករណ៍ដែលធ្វើឱ្យ

---

[14] សំណើសុំ កថាខណ្ឌ ២, ១៣ ដល់ ១៤។

[15] សំណើសុំ កថាខណ្ឌ ២, ១៥។

[16] សំណើសុំ កថាខណ្ឌ ២, ១០ ដល់ ១២, ១៤។

[17] សេចក្តីសម្រេចលើសំណើសុំរបស់សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ ឯកសារលេខ F10/2 កថាខណ្ឌ ១១ និង ១៤ ("សេចក្តីសម្រេចស្តីពីអត្ថិភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី")។

ប៉ះពាល់ដោយផ្ទាល់ដល់សិទ្ធិ និងអត្ថប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី។ ទីពីរ "សហមេធាវីនាំមុខត្រូវជៀសវាងភាពច្រំដែល និងការត្រួតគ្នាជាមួយនឹងបញ្ហាដែលបានលើកឡើងនៅក្នុងសារណាតបរបស់សហព្រះរាជអាជ្ញា"[18]។

13. អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ច្បាស់លាស់អំពីចេតនារបស់ខ្លួនក្នុងការឆ្លើយតបទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន "ត្រង់ចំណុចដែលធ្វើឱ្យប៉ះពាល់ដោយផ្ទាល់លើសិទ្ធិជាក់លាក់ និងអត្ថប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី" និង"ការយល់ឃើញអំពីតម្រូវការចាំបាច់ក្នុងការថ្លឹងថ្លែងតុល្យភាពនៃសិទ្ធិរបស់ភាគីនានាក្នុងអំឡុងពេលនៃកិច្ចដំណើរការនីតិវិធីបណ្តឹងសាទុក្ខ"។ អាស្រ័យហេតុនេះ សហមេធាវីនាំមុខ"ត្រូវជៀសវាងភាពច្រំដែល" និងការត្រួតគ្នាជាមួយនឹងសារណារបស់សហព្រះរាជអាជ្ញា[19]។

14. អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា សំណើនេះអាចទទួលយកបានតាមទម្រង់។

## IV. **ការពិភាក្សា**

### ក. ការបន្ថែមចំនួនទំព័រ

*១.ច្បាប់ជាធរមាន*

15. សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារ("សេចក្តីណែនាំអនុវត្ត")ចែងថា ឯកសារដែលដាក់ចំពោះមុខអង្គជំនុំជម្រះ មិនត្រូវលើស ៣០ ទំព័រជាភាសាអង់គ្លេស ឬបារាំង ឬ ៦០ ទំព័រជាភាសាខ្មែរ លើកលែងតែមានការបង្គាប់ផ្សេងពីនេះដោយអង្គជំនុំជម្រះ តាមសំណើរបស់ភាគីក្នុងកាលៈទេសៈពិសេស[20]។

*២.ការពិចារណា*

16. ដើមបណ្តឹងរដ្ឋប្បវេណីបានស្នើសុំបន្ថែមរហូតដល់ ៣២០ ទំព័រ។

---

[18] សេចក្តីសម្រេចស្តីពីអត្ថិភាពរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ១៧។

[19] សំណើសុំ កថាខណ្ឌ ២, ១៣។

[20] មាត្រា ៥.២ និង ៥.៣ នៃសេចក្តីណែនាំអនុវត្ត ។

17. អង្គជំនុំជម្រះរំលឹកថា អង្គជំនុំជម្រះបានទទួលស្គាល់នូវលក្ខណៈពិសេសរបស់សាលក្រមអង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងទំហំ និងភាពស្មុគស្មាញ និងយល់ឃើញថា កាលៈទេសៈពិសេសមានអត្ថិភាពតម្រូវឱ្យមានការបន្ថែមពេលវេលា និងចំនួនទំព័រ[21]។

18. អង្គជំនុំជម្រះបានទទួលស្គាល់ថា ខ្លឹមសារ"ទូលំទូលាយ" និងទ្រង់ទ្រាយនៃសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខធ្វើឱ្យដើមបណ្តឹងរដ្ឋប្បវេណីមានការលំបាកក្នុងការប្រមាណទំហំនៃសារណាតបរបស់ខ្លួន។ បន្ថែមលើនេះ អង្គជំនុំជម្រះទទួលស្គាល់ថា ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី *ជាក់ស្តែង* កប់នៅក្នុងការយល់ឃើញផ្នែកអង្គហេតុ និងអង្គច្បាប់ជាច្រើនដែលរងការជំទាស់នៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន។ អង្គជំនុំជម្រះបានកត់សម្គាល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីបានកំណត់អត្តសញ្ញាណនៃ"បញ្ហាខ្លឹមសារជាង ៤០ ចំណុច ជាប់ពាក់ព័ន្ធ ជាង ១០០ កថាខណ្ឌ ឬសេចក្តីសម្រេចដូចជា [...] ដែលទំនងជាប៉ះពាល់ដោយផ្ទាល់ទៅលើសិទ្ធិ និងអត្ថប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី" ព្រមទាំង"ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៦ រូប ដែលនឹងត្រូវធ្វើការជំទាស់ទៅលើភស្តុតាង" ទាំងនេះតម្រូវឱ្យមានការឆ្លើយតបនីមួយៗ និងជាក់លាក់ពីដើមបណ្តឹងរដ្ឋប្បវេណី។ អង្គជំនុំជម្រះកត់សម្គាល់ឃើញផងដែរថា "ចំនួនទាំងនេះតំណាងឱ្យការប៉ាន់ស្មានបឋមជាអប្បបរមា"ដោយផ្អែកលើមូលដ្ឋាននៃព័ត៌មានដែលមាននៅក្នុងសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ ខៀវ សំផន និងឧបសម្ព័ន្ធ[22]។

19. យោងតាមសំអាងហេតុខាងលើ អង្គជំនុំជម្រះយល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់យុត្តិកម្មសមស្របក្នុងការស្នើសុំបន្ថែម ៣២០ ទំព័រ អាស្រ័យហេតុនេះ អង្គជំនុំជម្រះអនុញ្ញាតតាមសំណើ។

## ខ. ការបន្ថែមពេលវេលា

### *១. ច្បាប់ជាធរមាន*

20. សេចក្តីណែនាំអនុវត្តចែងថា សារណាតបត្រូវតែដាក់ក្នុងរយៈពេល ១០ ថ្ងៃនៃប្រតិទិនគិតចាប់ពីការជូនដំណឹងនៃឯកសារដែលភាគីត្រូវឆ្លើយតប[23]។

---

[21] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ ថ្ងៃទី ២៣ ខែសីហា ឆ្នាំ ២០១៩ ឯកសារលេខ F49 កថាខណ្ឌ ១៤។

[22] សំណើសុំ កថាខណ្ឌ ១១ ដល់ ១២។

[23] មាត្រា ៨.៣ នៃសេចក្តីណែនាំអនុវត្ត។

21. វិធានផ្ទៃក្នុងចែងថា "ចៅក្រមអាចកំណត់ពេលវេលាសម្រាប់ដាក់សារណា សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងឯកសារពាក់ព័ន្ធទៅនឹងសំណើសុំណាមួយ ឬបណ្តឹងឧទ្ធរណ៍ ឬបណ្តឹងសាទុក្ខ ដោយគិតពិចារណាដល់កាលៈទេសៈនៃរឿងក្តីនោះ"[24]។ បន្ថែមលើនេះទៀត វិធានបានចែងថា "អង្គជំនុំជម្រះ អាចតាមរយៈពាក្យសុំរបស់ភាគីពាក់ព័ន្ធ [...] បន្ថែមពេលវេលាដែលខ្លួនបានកំណត់"[25]។

*២. ការពិចារណា*

22. អង្គជំនុំជម្រះយល់ស្របជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីថា ការផ្តល់ពេលវេលាឱ្យពិនិត្យលើសារណាតបរបស់សហព្រះរាជអាជ្ញានៅមុនការដាក់សារណាតបរបស់ខ្លួន គឺជាវិធីសាស្ត្រដ៏មានប្រសិទ្ធភាពខ្ពស់បំផុតក្នុងការជៀសវាងភាពត្រួតគ្នា និងភាពច្រំដែល[26]។ ហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីគប្បីផ្តល់ពេលវេលាបន្ថែមសម្រាប់ដាក់សារណាតបបន្ទាប់ពីសារណាតបរបស់សហព្រះរាជអាជ្ញា។

23. អង្គជំនុំជម្រះរំលឹកថា អង្គជំនុំជម្រះបានផ្តល់រយៈពេល ១២០ ថ្ងៃដល់សហព្រះរាជអាជ្ញាដាក់សារណាតបបន្ទាប់ពីការជូនដំណឹងនៃសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន[27]។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ក្នុងអំឡុងពេល ១២០ ថ្ងៃ ដើមបណ្តឹងរដ្ឋប្បវេណីអាចរៀបចំការងារជាបឋមមួយចំនួនធំលើសារណាបណ្តឹងសាទុក្ខរបស់ខ្លួនបាន។

24. អាស្រ័យហេតុនេះ អង្គជំនុំជម្រះយល់ឃើញថា រយៈពេលបន្ថែម ៦០ ថ្ងៃគិតចាប់ពីពេលជូនដំណឹងនៃសារណាតបរបស់សហព្រះរាជអាជ្ញា ជារយៈពេលមួយដ៏វែង និងពុំមានភាពចាំបាច់ឡើយ។ រយៈពេល ៤០ ថ្ងៃគិតចាប់ពីពេលជូនដំណឹងនៃសារណាតបរបស់សហព្រះរាជអាជ្ញា ជាការសមស្របសម្រាប់គោលបំណងតែមួយគត់គឺជៀសវាងភាពត្រួតគ្នា និងភាពច្រំដែលជាមួយនឹងសារណាតបរបស់សហព្រះរាជអាជ្ញា។

---

[24] វិធាន ៣៩(២) នៃវិធានផ្ទៃក្នុង។

[25] វិធាន ៣៩(៤) នៃវិធានផ្ទៃក្នុង។

[26] សំណើសុំ កថាខណ្ឌ ១៣។

[27] *សូមមើលខាងលើ* កថាខណ្ឌ ៥។

25. អាស្រ័យហេតុនេះ ដោយពិចារណាលើភាពចាំបាច់ក្នុងការធ្វើឱ្យមានតុល្យភាពនៃអត្ថប្រយោជន៍របស់ភាគីសម្រាប់កិច្ចដំណើរការនីតិវិធីទទួលបានប្រសិទ្ធភាព និងឆាប់រហ័ស[28] អង្គជំនុំជម្រះសម្រេចផ្តល់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤០ ថ្ងៃបន្ថែមសម្រាប់ដាក់សារណាតបរបស់ខ្លួន គិតចាប់ពីពេលជូនដំណឹងនៃសារណាតបរបស់សហព្រះរាជអាជ្ញា។

## គ. ការដាក់តែមួយភាសា

### *១. ច្បាប់ជាធរមាន*

26. សេចក្តីណែនាំអនុវត្តចែងថា "រាល់ឯកសារត្រូវតែដាក់ជាភាសាខ្មែរ និងភាសាអង់គ្លេស ឬបារាំង" ប៉ុន្តែ អង្គជំនុំជម្រះអាចក្នុងករណីពិសេស"អនុញ្ញាតឱ្យភាគីដាក់ឯកសារជាភាសាអង់គ្លេស ឬបារាំងជាមុន និងថា ការបកប្រែជាភាសាខ្មែរនឹងត្រូវដាក់នៅមុខអង្គជំនុំជម្រះឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន"[29]។

### *២. ការពិចារណា*

27. អង្គជំនុំជម្រះរំលឹកថា រាល់ភាគីត្រូវប្រឹងប្រែងគ្រប់ពេលវេលាក្នុងការគោរពតាមលក្ខខណ្ឌតម្រូវទូទៅនៃការដាក់ឯកសារជាពីរភាសាក្នុងពេលតែមួយនៅចំពោះមុខ អ.វ.ត.ក. និងថា សារៈសំខាន់នៃការដាក់សំណៅជាភាសាខ្មែរពុំត្រូវមើលរំលងឡើយជាពិសេសផ្អែកតាមភាពជាក់ស្តែងគឺថា "កាលបរិច្ឆេទចាប់គិតពីថ្ងៃទីមួយនៃការជូនដំណឹងឯកសារជាភាសាខ្មែរ និងភាសាផ្លូវការដទៃទៀតរបស់ អ.វ.ត.ក."[30]។

28. ផ្អែកតាមកាលៈទេសៈទាំងនេះ និងដោយមានការអនុញ្ញាតប្រហាក់ប្រហែលគ្នាចំពោះសហព្រះរាជអាជ្ញា និង ខៀវ សំផន ក្នុងការដាក់សារណាតប និងសារណាបណ្តឹងសាទុក្ខតែមួយភាសា[31] អង្គជំនុំ

---

[28] សេចក្តីលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងទំព័រ សម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F49 កថាខណ្ឌ ១៩ និង ការយោងត្រូវបានដកស្រង់។

[29] មាត្រា ៧.១ និង ៧.២ នៃសេចក្តីណែនាំអនុវត្ត។

[30] មាត្រា ៨.៥ នៃសេចក្តីណែនាំអនុវត្ត។ សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងទំព័រសម្រាប់សារណាបណ្តឹងសាទុក្ខ និងសារណាតបក្នុងសំណុំរឿង ០០២/០១ ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤ ឯកសារលេខ F9 កថាខណ្ឌ ២១។

[31] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F49 កថាខណ្ឌ ១៧ និង ៣៦។

ជម្រះអនុញ្ញាតឱ្យដើមបណ្តឹងរដ្ឋប្បវេណីដាក់សារណាតបរបស់ខ្លួនជាភាសាអង់គ្លេស ដែលការបកប្រែជាភាសាខ្មែរត្រូវដាក់តាមក្រោយឱ្យបានឆាប់បំផុត។

29. ដូចបានសម្រេចខាងលើ អង្គជំនុំជម្រះបញ្ជាក់សាជាថ្មីថា អង្គជំនុំជម្រះរំពឹងទុកថា ដើមបណ្តឹងរដ្ឋប្បវេណី រួមទាំង សហព្រះរាជអាជ្ញា និង ខៀវ សំផន ត្រូវប្រើប្រាស់ឱ្យបានប្រសើរបំផុតនូវធនធានផ្នែកភាសាដែលមាននៅក្នុងក្រុមរបស់ខ្លួន ស្របពេលជាមួយនឹងអង្គភាពបកប្រែដើម្បីឱ្យការបកប្រែសារណាតប និងសារណាបណ្តឹងសាទុក្ខជាភាសាខ្មែរកាន់តែឆាប់រហ័ស[32]។

## V. ផ្នែកសម្រេចសេចក្តី

30. យោងតាមសម្អាងហេតុខាងលើ **អង្គជំនុំជម្រះតុលាការកំពូល៖**

**ប្រកាស**ថា សំណើនេះអាចទទួលយកបានតាមទម្រង់

**ទទួលយក**ផ្នែកខ្លះនៃសំណើនេះ។

**បង្គាប់**ដើមបណ្តឹងរដ្ឋប្បវេណីដាក់សារណាតបរបស់ខ្លួនទៅនឹងសារណាបណ្តឹងសាទុក្ខរបស់ ខៀវ សំផន មិនឱ្យលើសពី ៣២០ ទំព័រជាភាសាអង់គ្លេស ឬបារាំង ដែលការបកប្រែជាភាសាខ្មែរត្រូវដាក់តាមក្រោយឱ្យបានឆាប់បំផុត ហើយត្រូវដាក់ក្នុងរយៈពេល ៤០ ថ្ងៃគិតចាប់ពីថ្ងៃជូនដំណឹងនៃសារណាតបរបស់សហព្រះរាជអាជ្ញា។

រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ ធ្នូ ឆ្នាំ ២០១៩

**ប្រធានអង្គជំនុំជម្រះតុលាការកំពូល**

**គង់ ស្រ៊ីម**

[32] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន សុំបន្ថែមពេលវេលា និងទំព័រសម្រាប់ដាក់សារណាបណ្តឹងសាទុក្ខ ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៩ ឯកសារលេខ F49 កថាខណ្ឌ ១៩។